# អនុស្សរណៈ
# រវាងរាជរដ្ឋាភិបាលកម្ពុជា
# និង
# ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស សម្រាប់ការអនុវត្តកម្មវិធីនៃកិច្ចសហប្រតិបត្តិការ បច្ចេកទេសស្តីពីបញ្ហាសិទ្ធិមនុស្ស

**ដោយបញ្ជាក់ជាថ្មី** អំពីគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ

**ដោយយល់ថា** អនុលោមតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៩២៦(X) ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ១៩៥៥ មហាសន្និបាតបានបង្កើតឡើងនូវកម្មវិធីសេវាប្រឹក្សាផ្តល់យោបល់របស់អង្គការសហប្រជាជាតិខាងវិស័យសិទ្ធិមនុស្ស ដែលត្រូវផ្តល់ដោយលោកអគ្គលេខាធិការតាមការស្នើសុំរបស់រដ្ឋាភិបាលនានា

**ដោយយល់ថា** អនុលោមតាមកិច្ចព្រមព្រៀងនានារវាងអង្គការសហប្រជាជាតិ ដែលជាអ្នកគ្រប់គ្រង និងបណ្តាប្រទេសផ្តល់ជំនួយចំពោះអតីតមូលនិធិវិភាគទានស្ម័គ្រចិត្តសម្រាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ហើយមូលនិធិនេះ ត្រូវបានផ្ទេរដោយការទុកចិត្តទៅការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (ក្នុងឯកសារនេះហៅកាត់ថា៖ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស OHCHR) សម្រាប់ធ្វើសកម្មភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា

**ដោយយល់ថា** កន្លងមករាជរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានបន្តអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការក្នុងវិស័យសិទ្ធិមនុស្ស ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេស

**ដោយយល់ថា** ក្នុងគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការដែលមានស្រាប់មកហើយ

**ដោយយល់ថា** រាជរដ្ឋាភិបាលកម្ពុជា និងអង្គការកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីផ្តល់ជំនួយឧបត្ថម្ភតាមបទដ្ឋានជាចាំបាច់កាលពីខែធ្នូ ឆ្នាំ១៩៩៤ (ក្នុងឯកសារនេះ ហៅកាត់ថា SBAA)

**ដោយហេតុនេះ** ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស (OHCHR) និងរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (ក្នុងឯកសារនេះហៅកាត់ថា "រាជរដ្ឋាភិបាល") ជាភាគីនៃអនុស្សរណៈនេះ បានព្រមព្រៀងគ្នាដូចតទៅ៖

## I. ទិសដៅ

## ប្រការ ១

## គោលបំណងនៃអនុស្សរណៈ

គោលបំណងរបស់អនុស្សរណៈ គឺដើម្បីប្រកាសអំពីបំណងប្រាថ្នារបស់ភាគីទាំងពីរសហការគ្នា ដើម្បីអនុវត្តកម្មវិធីសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស (នៅក្នុងឯកសារនេះហៅកាត់ថា "កម្មវិធី") និងបង្កើតក្របខ័ណ្ឌមួយសម្រាប់កិច្ចសហប្រតិបត្តិការ ដោយឈរលើមូលដ្ឋាននៃគោលបំណង និងគោលការណ៍ដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ជាពិសេសមាត្រា ២(៧)។

## II. ការពិពណ៌នាអំពីកម្មវិធី

## ប្រការ ២

## វត្តមាននៃកិច្ចប្រតិបត្តិការរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា

២.១. ភាគីទាំងពីរយល់ព្រមបន្តវត្តមាននៃកិច្ចប្រតិបត្តិការរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំនៅកម្ពុជាសម្រាប់រយៈពេលពីរឆ្នាំទៀត ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០២១ ក្នុងគោលបំណងអនុវត្តកម្មវិធីសកម្មភាពសហប្រតិបត្តិការផ្នែកបច្ចេកទេស ដើម្បីជួយអនុវត្តកម្មវិធីនៃកិច្ចសហប្រតិបត្តិការដូចដែលមានចែងនៅក្នុងអនុស្សរណៈនេះ។

២.២. ក្នុងរយៈពេលពីរខែយ៉ាងតិច មុនការបញ្ចប់សុពលភាពនៃអនុស្សរណៈ ភាគីទាំងពីរត្រូវធ្វើការវាយតម្លៃរួមគ្នាមួយអំពីភាពរីកចំរើននៃការអនុវត្តគម្រោងកម្មវិធីនេះ និងត្រូវរៀបចំគម្រោងកម្មវិធីថ្មីសម្រាប់អាណត្តិពីរឆ្នាំទៅមុខទៀត។

## ប្រការ ៣
## គម្រោងការផ្សេងៗ

៣.១. ភាគីទាំងពីរបានយល់ស្របដូចគ្នាថា សកម្មភាពនានានៃការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស និងកម្មវិធីសហប្រតិបត្តិការផ្នែកបច្ចេកទេស ត្រូវបានរៀបចំឡើងដើម្បីពង្រឹងបន្ថែមទៀតនូវសមត្ថភាពរបស់ស្ថាប័នរាជរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាលដើម្បីជំរុញនិងការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។

៣.២. ភាគីទាំងពីរបានយល់ស្របដូចគ្នាដែរថា កម្មវិធីត្រូវរួមបញ្ចូលនូវគម្រោងការនានា ដែលមានចែងក្នុងកថាខ័ណ្ឌនេះ ព្រមទាំងគម្រោងការផ្សេងៗទៀតដែលភាគីទាំងពីរព្រមព្រៀងគ្នា។ គម្រោងការទាំងនេះ នឹងត្រូវអនុវត្តដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស តាមរយៈវត្តមាននៃកិច្ចប្រតិបត្តិការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ដោយសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល។ គម្រោងការទាំងនេះរួមមានវិស័យសំខាន់ៗ ដូចតទៅ៖

(១) បន្តផ្តល់ជំនួយឧបត្ថម្ភដល់រាជរដ្ឋាភិបាល ក្នុងការជំរុញ និងការការពារសិទ្ធិមនុស្ស។

(២) ជំរុញការបញ្ចូលវិស័យសិទ្ធិមនុស្សឱ្យកាន់តែទូលំទូលាយថែមទៀត ទៅក្នុងកម្មវិធីអប់រំសុខាភិបាល និងកម្មវិធីអភិវឌ្ឍន៍ដទៃទៀត ដោយសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា។

(៣) ផ្តល់ការបណ្តុះបណ្តាលបន្ថែមទៀតដល់មន្ត្រីអនុវត្តច្បាប់ និងយោធា ក្នុងគោលបំណងបង្កើនចំណេះដឹងរបស់គេ អំពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដើម្បីគាំទ្រដល់កម្មវិធីរៀបចំរចនាសម្ព័ន្ធឡើងវិញ និងកម្មវិធីកែទម្រង់របស់រដ្ឋាភិបាល។

(៤) ផ្តល់ការគាំទ្រខាងបច្ចេកទេសដល់កម្មវិធីកែទម្រង់របស់រដ្ឋាភិបាល រួមទាំងវិស័យនៃការគ្រប់គ្រងផ្នែកយុត្តិធម៌ និងដំណើរការនីតិកម្ម និងដើម្បីជួយលើកទឹកចិត្តឱ្យមានការចូលរួមពីសង្គមស៊ីវិល និងដើម្បីលើកស្ទួយការអប់រំសាធារណៈ អំពីលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ជាពិសេសក្នុងវិស័យសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

(៥) ការផ្តល់ជំនួយបច្ចេកទេស និងផ្តល់យោបល់ យោងតាមការស្នើសុំរបស់រាជរដ្ឋាភិបាល ដើម្បីបំពេញការទទួលខុសត្រូវរបស់ខ្លួន រួមមានការដាក់ជូនរបាយការណ៍នានារបស់កម្ពុជា ដែលជាកាតព្វកិច្ចរបស់ខ្លួន ស្របតាមសន្ធិសញ្ញាអន្តរជាតិផ្នែកសិទ្ធិមនុស្សនានា។

(៦) ការផ្តល់យោបល់ និងឧបត្ថម្ភដល់រាជរដ្ឋាភិបាល និងសង្គមស៊ីវិលជាដៃគូរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើតស្ថាប័នជាតិផ្នែកសិទ្ធិមនុស្សមួយ ហើយជួយបណ្តុះបណ្តាលបុគ្គលិកនៃស្ថាប័ននេះ អំពីសិទ្ធិមនុស្ស។

(៧) ការផ្តល់ជំនួយឧបត្ថម្ភចាំបាច់ផ្សេងទៀត តាមការស្នើសុំរបស់រាជរដ្ឋាភិបាល និងតាមការព្រមព្រៀងរបស់ភាគីទាំងពីរ។

៣.៣ គម្រោងការទាំងនេះ ត្រូវអនុវត្តដោយអង្គភាពផ្សេងៗ របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស តាមរយៈ៖

(ក) សេវាប្រឹក្សា និងជំនួយផ្នែកបច្ចេកទេស

(ខ) វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា

(គ) ការចងក្រងឯកសារ និងការផ្តល់ព័ត៌មាន និង

(ឃ) ការគាំទ្រដល់សង្គមស៊ីវិល ដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

៣.៤ ជំនួយបច្ចេកទេស និងប្រឹក្សា ដែលត្រូវបានផ្តល់ដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស តាមការស្នើសុំរបស់រាជរដ្ឋាភិបាល ត្រូវអនុលោមទៅតាមនីតិវិធីអនុវត្តទាំងឡាយនៃការផ្តល់ជំនួយបច្ចេកទេសរបស់អង្គការសហប្រជាជាតិ។

## ប្រការ ៤

## ការទទួលខុសត្រូវរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ត្រូវទទួលខុសត្រូវក្នុងការ៖

(ក) ផ្តល់មន្ត្រី អ្នកជំនាញការ និងទីប្រឹក្សាដែលចាំបាច់តាមតម្រូវការ ដើម្បីរៀបចំ និងចាត់ចែងគម្រោងការនានា ឬដើម្បីអនុវត្តកម្មវិធីសកម្មភាព ដូចបានគូសបញ្ជាក់ក្នុងប្រការ ៣ ខាងលើ។

(ខ) បន្តការពិគ្រោះយោបល់ជាប្រចាំជាមួយរាជរដ្ឋាភិបាល លើរាល់បញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តន៍កម្មវិធីសកម្មភាពផ្សេងៗ រួមទាំងបទប្បញ្ញត្តិនៃប្រការ ៤ (ក) ខាងលើ ។

(គ) ផ្តល់ព័ត៌មានជាមុនចំពោះរាជរដ្ឋាភិបាល អំពីកម្មវិធីទស្សនកិច្ចផ្លូវការមកកាន់ប្រទេសកម្ពុជារបស់មន្ត្រីអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស រួមទាំងការស្នើសុំទិដ្ឋាការចូលសម្រាប់ភ្ញៀវទាំងអស់ស្របតាមបទប្បញ្ញត្តិរបស់កម្ពុជា។

(ឃ) ទទួលបន្ទុកការចំណាយលើសោហ៊ុយធ្វើដំណើរ និងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ សម្រាប់មន្ត្រីអង្គការសហប្រជាជាតិ អ្នកជំនាញការ និងទីប្រឹក្សា ដែលការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស បានផ្តល់ជូនរាជរដ្ឋាភិបាល ស្របតាមបែបបទដែលមានចែងនៅក្នុងកម្មវិធីសេវាប្រឹក្សារបស់អង្គការសហប្រជាជាតិ ក្នុងវិស័យសិទ្ធិមនុស្ស។

(ង) ផ្តល់ជូនរាជរដ្ឋាភិបាលនូវរបាយការណ៍ និងអនុសាសន៍ដែលរៀបចំឡើងដោយអ្នកជំនាញការ និងទីប្រឹក្សាខាងលើ។

(ច) សម្រួល និងរ៉ាប់រងលើចំណាយសម្រាប់សំភារៈទាំងអស់ ដែលចាំបាច់សម្រាប់កម្មវិធីដែលពាក់ព័ន្ធទៅនឹងគម្រោងការនានាខាងលើនេះ និង

(ឆ) ផ្តល់ជូនរាជរដ្ឋាភិបាលនូវបញ្ជីឈ្មោះថ្មីៗនៃបុគ្គលិកបរទេស និងបុគ្គលិកក្នុងស្រុកឱ្យបានទៀងទាត់។

## ប្រការ ៥

## ការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការៈ

(ក) ជូនព័ត៌មានដល់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អំពីសេចក្តីត្រូវការជាពិសេសណាដែលរាជរដ្ឋាភិបាលមានបំណងចង់ឱ្យការិយាល័យឆ្លើយតប ក្នុងការអនុវត្តន៍កម្មវិធី អំពីសកម្មភាពដែលរាជរដ្ឋាភិបាលបានចាត់ឡើង ដើម្បីអនុវត្តតាមយោបល់របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស និងអំពីព័ត៌មានពាក់ព័ន្ធ ដែលជួយដល់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សក្នុងការបំពេញអាណត្តិរបស់ខ្លួន។

(ខ) ជួយដល់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស តាមការស្នើសុំរបស់ការិយាល័យក្នុងការអញ្ជើញអ្នកក្នុងស្រុកចូលរួម រួមទាំងមន្ត្រីរាជរដ្ឋាភិបាលផង សម្រាប់សកម្មភាពនានាដែលបានលើកឡើងនៅក្នុងគម្រោងការនៃកម្មវិធីដែលមានចែងនៅក្នុងប្រការ ៣ ខាងលើ និង

(គ) ធានាសន្តិសុខដល់បុគ្គលទាំងអស់ ដែលមានចែងនៅក្នុងប្រការ ៧ ខាងក្រោម ដែលកំពុងបំពេញមុខងារជាផ្លូវការ ដូចមានចែងក្នុងប្រការ ៣ និង ប្រការ ៤ ខាងលើ ព្រមទាំងទ្រព្យសម្បត្តិ និងទីតាំងរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ដែលត្រូវបានប្រើប្រាស់ក្នុងការអនុវត្តអនុស្សរណៈនេះ។

## III. ការផ្តល់ហិរញ្ញប្បទាន

### ប្រការ ៦

### ការផ្តល់ហិរញ្ញប្បទាន

៦.១ ភាគីទាំងពីរ បានយល់ស្របគ្នាថា សកម្មភាពនានារបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ដូចបានរៀបរាប់នៅក្នុងប្រការ ៤ ខាងលើ ក៏ដូចជាសកម្មភាពផ្សេងៗដទៃទៀត អនុវត្តដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ស្របតាមអនុស្សរណៈនេះ សម្រាប់អនុវត្តកម្មវិធីដែលត្រូវបានផ្តល់ថវិកាដោយមូលនិធិវិភាគទានស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ សម្រាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ឬ ដោយមូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិដទៃទៀត គ្រប់គ្រងដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស តាមដែលការិយាល័យយល់ថាសមស្រប។

៦.២ រាជរដ្ឋាភិបាល ដែលតំណាងដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ព្រមព្រៀងគ្នាថានឹងធ្វើការពិគ្រោះពិភាក្សាគ្នាជាទៀងទាត់ មួយត្រីមាសម្តង ដើម្បីកសាងកម្មវិធីការងារមួយក្នុងក្របខ័ណ្ឌធនធានដែលមាន។ កម្មវិធីនេះ នឹងត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ និងកែតម្រូវទៅតាមថវិកាដែលមាន និងឬតាមការរីកចម្រើនដែលសម្រេចបាន។

៦.៣ ភាគីទាំងពីរបានយល់ស្រប និងព្រមព្រៀងគ្នាថា ការអនុវត្តដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ក្នុងការទទួលខុសត្រូវរបស់ខ្លួននោះ គឺអាស្រ័យទៅតាមលទ្ធភាពនៃថវិកាដែលមាន ដូច្នេះ នៅពេលណាក៏ដោយ ក្នុងរយៈពេលអនុវត្តកម្មវិធីនេះ បើសិនជាមានការខ្វះខាតថវិកា ភាគីទាំងពីរត្រូវពិគ្រោះយោបល់គ្នាទៅវិញទៅមក ក្នុងគោលបំណងស្វែងរកថវិកាដែលត្រូវការនោះ។ បើសិនមិនអាចរកថវិកានេះបានទេ កម្មវិធី ឬ គម្រោងការណាមួយ (ឬ ច្រើន) ក្រោមកម្មវិធីនេះអាចនឹងត្រូវកាត់បន្ថយ កែសម្រួលឬបញ្ឈប់ដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សបាន ដោយមានការពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាល។

## IV. បែបបទផ្លូវច្បាប់សម្រាប់យកមកអនុវត្តចំពោះគម្រោងសកម្មភាពផ្សេងៗ និងវត្តមានកិច្ចប្រតិបត្តិការរបស់ការិយាល័យ

### ប្រការ ៧

### បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ

៧.១ រាជរដ្ឋាភិបាលយល់ព្រមអនុវត្តបទប្បញ្ញត្តិនានារបស់ (UNDP/SBAA) ចំពោះសកម្មភាព និងបុគ្គលិកទាំងអស់របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ព្រមទាំងទ្រព្យសម្បត្តិ និងទីតាំងរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ដែលត្រូវបានប្រើប្រាស់ទាក់ទងនឹងវត្តមានប្រតិបត្តិការរបស់ការិយាល័យ។

៧.២ អ្នកជំនាញការ ដែលត្រូវបានអញ្ជើញដោយអង្គការសហប្រជាជាតិ ដើម្បីដឹកនាំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងសកម្មភាពដូចគ្នានេះដទៃទៀត ត្រូវបានចាត់ទុកថាជាអ្នកជំនាញការ ដែលកំពុងបំពេញបេសកកម្មសម្រាប់អង្គការសហប្រជាជាតិ។

៧.៣ ទាក់ទងដល់សកម្មភាពនៃកម្មវិធីទាំងអស់ ព្រមទាំងសកម្មភាពនៃវត្តមានប្រតិបត្តិការរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស៖

(ក) មន្ត្រីអង្គការសហប្រជាជាតិ អ្នកជំនាញការ ទីប្រឹក្សា បុគ្គលិកទាំងឡាយដែលបម្រើការ ឬអ្នកដែលចូលរួមក្នុងសកម្មភាព ដែលមានចែងក្នុងប្រការ ៣ និង ៤ ខាងលើ ត្រូវបានផ្តល់នូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងអស់ ស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងនៅក្នុងប្រការ IX នៃ UNDP/SBAA តាមការចាំបាច់។

(ខ) មន្ត្រីរបស់ទីភ្នាក់ងារជំនាញ ដែលចូលរួមសកម្មភាពទាំងនេះ ត្រូវបានផ្តល់នូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ស្របតាមអនុសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ទីភ្នាក់ងារជំនាញ។

(គ) ដោយមិនប៉ះពាល់ទៅលើបទបញ្ញត្តិនៃ UNDP/SBAA អ្នកជំនាញការ និងបុគ្គលទាំងអស់ដែលបំពេញមុខងារជាផ្លូវការ ត្រូវបានផ្តល់នូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ និងការជួយសម្រួលនិងផ្តល់បោរីភាពដែលជាការចាំបាច់សម្រាប់ការបំពេញកិច្ចការរបស់ខ្លួនដោយឯករាជ្យ។

(ឃ) ដោយមិនប៉ះពាល់ទៅលើបទបញ្ញត្តិនៃអនុញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជាគោរពសេរីភាពក្នុងការបញ្ចេញមតិទាំងស្រុងរបស់អ្នកចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងសកម្មភាពផ្សេងៗដូចគ្នានេះដែរ ដែលរៀបចំឡើងដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ស្របតាមគោលការណ៍ និងការអនុវត្តដែលពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ។

(ង) អ្នកជំនាញការ និងមន្ត្រីអង្គការសហប្រជាជាតិទាំងអស់ ព្រមទាំងបុគ្គលិកទាំងអស់ដែលបំពេញមុខងារជាផ្លូវការទាក់ទងទៅនឹងសកម្មភាពនៃកម្មវិធី ត្រូវបានផ្តល់ការជួយសម្រួលដូចមានចែងក្នុងប្រការ X នៃ UNDP/SBAA ។

## ប្រការ ៨
## ការប្តឹងតវ៉ានានាប្រឆាំងនឹងអង្គការសហប្រជាជាតិ

ចំពោះការប្តឹងតវ៉ានានា ប្រឆាំងនឹងអង្គការសហប្រជាជាតិដោយភាគីទីបី ដែលបានកំណត់នៅក្នុងប្រការ X (2) នៃ UNDP/SBAA ដែលទាក់ទងនឹងការអនុវត្តកម្មវិធីនេះ ត្រូវដោះស្រាយដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយ ដែលបានចែងនៅក្នុងប្រការ X (2) នៃ UNDP/SBAA។

## ប្រការ ៩

## ការដោះស្រាយជម្លោះ

ភាគីទាំងពីរបានយល់ស្រប និងព្រមព្រៀងគ្នាថា បើមានវិវាទណាមួយរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលដែលកើតឡើង ឬដែលទាក់ទងនឹងកម្មវិធី និងគម្រោងការណាមួយ ដែលបានព្រមព្រៀងគ្នាហើយនោះ ត្រូវដោះស្រាយឱ្យស្របទៅតាមបទប្បញ្ញត្តិ ដែលបានចែងនៅក្នុងប្រការ XII នៃ UNDP/SBAA។

## ប្រការ ១០

## វិសោធនកម្ម

អនុស្សរណៈនេះ អាចធ្វើការកែប្រែបាន ដោយមានការព្រមព្រៀងគ្នាជាលាយល័ក្ខអក្សររវាងភាគីទាំងពីរ។

## ប្រការ ១១

## ការចូលជាធរមាន និងថេរវេលា

អនុស្សរណៈនេះត្រូវចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ សម្រាប់រយៈពេល ០២ ឆ្នាំ នឹងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

បានចុះហត្ថលេខានៅថ្ងៃទី...៣១... ខែធ្នូ ឆ្នាំ២០២០ នៅរាជធានីភ្នំពេញ និង

នៅថ្ងៃទី....11.....ខែ...January....ឆ្នាំ២០២១ នៅទីក្រុងហ្សឺណែវ ជាភាសាអង់គ្លេស និងភាសាខ្មែរ។

ក្នុងករណីមានការខ្វែងយោបល់គ្នាក្នុងការបកស្រាយ អត្ថបទជាភាសាអង់គ្លេស ត្រូវយកជាអត្ថបទគោល។

| ជួសមុខរាជរដ្ឋាភិបាលកម្ពុជា | ជួសមុខអង្គការសហប្រជាជាតិ |
|---|---|
| [signature] | [signature] |
| **ប្រាក់ សុខុន** | **មីស្ហែល បាឆេឡេ ជីរៀ** |
| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អង្គការសហប្រជាជាតិ ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស |